**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ..១១៩៤០.....អពជ

# សារលិខិតថ្វាយព្រះពរ

## ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា
## នៅក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាគម្រប់ ៦៧ យាងចូល ៦៨ ព្រះវស្សា
## ថ្ងៃទី១៤ ខែឧសភា ឆ្នាំ ២០២០

**ព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត!**

ក្នុងឱកាសដ៏មហាមង្គលាភិរម្យ ឧត្តុង្គឧត្តម ប្រសើរថ្លៃថ្លា នៃព្រះរាជពិធីបុណ្យចម្រើនព្រះជន្មវស្សាគម្រប់ ៦៧ យាងចូល ៦៨ ព្រះវស្សា របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០ នេះ ទូលព្រះបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំ មន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ សូមព្រះបរមរាជានុញ្ញាតសម្តែង នូវកតញ្ញូកតវេទិតាធម៌យ៉ាងជ្រាលជ្រៅបំផុត ចំពោះព្រះរាជហឫទ័យ និងព្រះរាជសកម្មភាពដ៏ឧត្តុង្គឧត្តមរបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូង ដែលព្រះអង្គបានបំពេញព្រះរាជកិច្ចដ៏មហាធំធេង និងបូជាព្រះកាយពលគ្រប់កាលៈទេសៈប្រកបដោយទសពិធរាជធម៌ ព្រះគុណធម៌ និងព្រះរាជបញ្ញាញាណដ៏ឈ្លាសវៃ ជាមួយគ្នានេះព្រះអង្គបាននឹងកំពុងបំពេញព្រះរាជបេសកកម្ម បម្រើជាតិ ព្រមទាំងបរិច្ចាគព្រះរាជទ្រព្យយ៉ាងច្រើនក្នុងការលើកស្ទួយវិស័យសិល្បៈវប្បធម៌ មនុស្សធម៌ សង្គមកិច្ច និងសុខមាលភាពសង្គម ដើម្បីបុព្វហេតុជូនដល់មាតុភូមិអង្គរដ៏បវរ និងប្រជានុរាស្ត្រជាទីស្នេហារបស់ព្រះអង្គ។

ឆ្លៀតក្នុងឱកាសដ៏មហានក្ខត្តឫក្សអភិសិរីភទ្របវរថ្លៃថ្លានេះផងដែរ ទូលព្រះបង្គំជាខ្ញុំ សូមលំឱនកាយវាចាចិត្តលើកហត្ថប្រណម្យបង្គំអញ្ជលី ព្រះបរមរាជានុញ្ញាត សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យកែវទាំងបី វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាព្រះមហាស្វេតច្ឆត្រ គុណបុណ្យព្រះបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ បារមីតេជានុភាពព្រះវិញ្ញាណក្ខន្ធនៃព្រះករុណា ព្រះបរមរតនកោដ្ឋ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ជាពិសេសទេវតាឆ្នាំថ្មី ឆ្នាំជូត ទោស័ក សូមព្រះមេត្តាតាមជួយគ្រងអភិបាលរក្សាការពារថ្វាយ ព្រះករុណាថ្លៃវិសេស ដើម្បីព្រះអង្គគង់ប្រថាប់ក្នុងព្រះសិរីរាជសម្បត្តិជាម្លប់ដ៏ត្រជាក់ត្រជុំ និងសេចក្តីសុខក្សេមក្សាន្តដល់ប្រជារាស្ត្រទូទាំងព្រះរាជាណាចក្រកម្ពុជា។

សូម ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះមេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ ប្រកបដោយភក្តីភាពដ៏ស្មោះស្ម័គ្របំផុតអំពីទូលព្រះបង្គំជាខ្ញុំ។

ថ្ងៃ ចន្ទ ៤រោច ខែ ពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ២០២០
**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh